00656143

E9/18

**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ប.ជ
ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: ខ្មែរ
កាលបរិច្ឆេទឯកសារ: ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់បំផុត
ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ: **សាធារណៈ / Public**
ឋានៈនៃចំណាត់ថ្នាក់ឯកសារ:
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

**សំណើសុំឲ្យទទួលយកការដាក់ឯកសារដែលយឺតយ៉ាវដោយអនុលោមតាម មាត្រា ១០.២ និង ៩ នៃសេចក្តីណែនាំអនុវត្ត**

**ដាក់ដោយ៖**
**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**
លោក ពេជ អង្គ
លោកស្រី Elisabeth SIMONNEAU FORT

**ផ្ញើជូន៖**
**អង្គជំនុំជម្រះសាលាដំបូង៖**
ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី
**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Andrew T. CAYLEY
**ជនជាប់ចោទ និងសហមេធាវីការពារក្តី៖**

**អៀង សារី**
លោក អាង ឧត្តម
លោក Michael G. KARNAVAS
**អៀង ធីរិទ្ធ**
លោក ផាត់ ពៅស៊ាង
លោកស្រី Diana ELLIS
**នួន ជា**
លោក សុន អរុណ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 01 / 04 / 2011
ម៉ោង (Time/Heure): 11:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

លោក Michiel PESTMAN

លោក Victor KOPPE

**ខៀវ សំផន**

លោក ស សូវ៉ាន

លោក Jacques VERGES

លោក Philippe GRECIANO

**<u>សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

លោកស្រី ស៊ិន សុវ៉ន លោក ឡោ ជុនធី

លោក ហុង គីមសួន លោក គីម ម៉េងឃី

លោក គង់ ពិសី លោក វ៉ែន ពៅ

លោក យុង ផានិត លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា លោកស្រី ម៉ុច សុវណ្ណារី

លោក Julien RIVET លោក Daniel LOSQ

លោក Pascal AUBOIN លោក Barnabe NEKUIE

លោកស្រី Silke STUDZINSKY

លោកស្រី Martine JACQUIN

លោក Philippe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Olivier BAHOUGNE

លោកស្រី Lyma NGUYEN

លោក Mahdev MOHAN

លោកស្រី Marie GUIRAUD

លោក Patrick BAUDOIN

លោកស្រី Fabienne TRUSSES-NAPROUS

លោក Ferdinand DJAMMEN-NZEPA

លោកស្រី Christine MARTINEAU

លោកស្រី Laure DESFORGES

លោកស្រី Isabelle DURAND

លោកស្រី Françoise GAUTRY

លោក Emmanuel ALTIT

លោក Emmanuel JACOMY

១. នៅថ្ងៃទី ១៦ មីនា ២០១១ ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ការដាក់ឯកសារតាមប្រព័ន្ធអេឡិចត្រូនិច ដែលមានចំណងជើងថា ឧបសម្ព័ន្ធ ៥៖ បញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺមិនទាន់ពេញលេញនោះទេ ។

២. ជាការពិត នៅថ្ងៃទី ១៤កុម្ភៈ ២០១១ លោកស្រី Silke STUDZINSKY សហមេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានផ្ញើរឯកសារ ឧបសម្ព័ន្ធ ៥ និង ឧបសម្ព័ន្ធ ៦ ៖ បញ្ជីឈ្មោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជូន សហមេធាវីនាំមុខ តំណាងដើមបណ្តឹងរដ្ឋប្បវេណី (សហមេធាវីនាំមុខ) ។

៣. នៅថ្ងៃទី ១៥ កុម្ភៈ ២០១១ លោកស្រី STUDZINSKY បានធ្វើការកែប្រែមួយចំនួនលើឯកសារឧបសម្ព័ន្ធទាំងនោះ ។

៤. នៅថ្ងៃទី ១៩ កុម្ភៈ ២០១១ លោកស្រី STUDZINSKY បានដាក់ឯកសារទាំងនោះ ជូនអង្គជំនុំ ជម្រះសាលាដំបូង ដោយញែកជាពីរឯកសារ គឺឧបសម្ព័ន្ធ ៥ និង ឧបសម្ព័ន្ធ ៦ ដើម្បីឲ្យមានភាពច្បាស់លាស់ ។ ដូច្នេះ សហមេធាវីនាំមុខមិនអាច ចុះហត្ថលេខាលើឯកសារទាំងនោះបានទេពីព្រោះ លោកស្រី STUDZINSKY បានសម្រេចដាក់ឯកសារនោះ ជូនអង្គជំនុំជម្រះ សាលាដំបូងដោយមិនឆ្លងតាមរយៈ សហ មេធាវីនាំមុខទេ ។

៥. នៅថ្ងៃទី ២១ កុម្ភៈ ២០១១ លោកស្រី STUDZINSKY បានធ្វើការកែប្រែមួយថ្មីទៀតលើឯកសារឧបសម្ព័ន្ធទាំងនោះ ដោយដាក់បញ្ចូលឈ្មោះ លោក សំ សុខគង់ សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

៦. នៅថ្ងៃទី ២៤ កុម្ភៈ ២០១១ លោកស្រី STUDZINSKY បានសួរ លោកស្រី Susan LAMB មន្ត្រីច្បាប់ជាន់ខ្ពស់ ថាតើអង្គជំនុំជម្រះសាលាដំបូងនិងចាត់ទុក ឯកសារដែលគាត់បានដាក់ជូននោះថាជាឯកសារដែលបានដាក់ត្រឹមត្រូវទាន់ពេលវេលា ឬទេ ។

៧. នៅថ្ងៃទី ២៤ កុម្ភៈ ២០១១ ដដែល លោកស្រី LAMB បានឆ្លើយទៅលោកស្រី STUDZINSKY ដោយប្រកាសថា ឯកសារដែលបានដាក់ដោយលោកស្រី STUDZINSKY នោះ មិនអាចទទួលយកបានទេ ហើយឯកសារទាំងនេះត្រូវចុះហត្ថលេខា និង ដាក់ដោយសហមេធាវីនាំមុខ ។

៨. នៅថ្ងៃទី ២៤កុម្ភៈ ២០១១ ដដែលនោះ លោកស្រី STUDZINSKY បានផ្ញើរសារអ៊ីមែលឆ្លើយទៅលោកស្រី LAMB ដោយអះអាងថា នេះមិនមែនជាផលប្រយោជន៍រួម នៃក្រុមរួមដើមបណ្តឹង

រដ្ឋប្បវេណីនោះទេ ។ ដូចនេះ សហ មេធាវីនាំមុខ មិនអាចចុះហត្ថលេខាលើ ឯកសារទាំងនេះបានទេ ពីព្រោះ ឯកសារទាំងនេះ ស្ថិតនៅក្នុងដៃរបស់ លោកស្រី STUDZINSKY ។

៩. នៅថ្ងៃទី ២៥ កុម្ភៈ ២០១១ លោកស្រី LAMB បានបញ្ជាក់ឡើងវិញនូវ សារអ៊ីមែលដំបូងរបស់គាត់ ហើយលោកស្រី STUDZINSKY បានផ្ញើរសារអ៊ីមែល ទៅសហមេធាវីនាំមុខ ដោយអះអាងនូវគោលជំហរ របស់គាត់ថា ថ្វីបើ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់បង្កើតជាក្រុមរួមក៏ដោយ ក៏វានៅតែមានផលប្រយោជន៍ ដោយឡែករបស់ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនស្ថិតនៅក្នុងតួនាទីរបស់សហមេធាវីនាំមុខនោះទេ ។ ឆ្លើយតប នឹងសារនេះ សហមេធាវីនាំមុខ បានពន្យល់លោកស្រី STUDZINSKY តាមរយៈសារអ៊ីមែល ថា វិធាន ២៣.៣ បញ្ជាក់អះអាងអំពីក្រុមរួម ដើមបណ្តឹងរដ្ឋប្បវេណី ។ ខណៈពេលនោះ សហមេធាវីនាំមុខបញ្ជាក់ថា ពួកគាត់យល់ព្រមចុះហត្ថលេខាលើឯកសារទាំងនោះ ប្រសិនបើមិនផ្ទុយនឹង ក្រុមរួម ដើមបណ្តឹងរដ្ឋប្បវេណី ។

១០. ត្រង់ចំណុចនេះ លោកស្រី STUDZINSKY បានរក្សានូវជំហររបស់គាត់ដដែល ។

១១. ទាក់ទងនឹងការដាក់ឯកសារនេះ លោកស្រី STUDZINSKY បានផ្ញើរឯកសារដោយផ្ទាល់ទៅក្រឡាញ្ជី ។ ហើយនៅថ្ងៃទី ៣ មីនា ២០១១ លោកស្រី LAMB បានឆ្លើយទៅលោកស្រី STUDZINSKY ថា ការដាក់ឯកសាររបស់ លោកស្រី STUDZINSKY មិនត្រូវបានទទួលយកដោយ អង្គជំនុំជម្រះសាលាដំបូង នោះទេ ហើយទង្វើដែលគាត់ស្វែងរកណែនាំ ដល់មន្ត្រីផ្សេងៗរបស់តុលាការបែបនេះ គឺជាទង្វើដែល មិនអាច ទទួលយកបានទាល់តែសោះ ហើយពួកគេមិនអាចធ្វើអ្វីតាមការណែនាំនេះ បានឡើយ ។

១២. នៅថ្ងៃទី ៩ មីនា ២០១១ លោកស្រី STUDZINSKY បានមករកសហមេធាវី នាំមុខដើម្បីធ្វើបណ្តឹង ឧទ្ធរណ៍លើការប្រកាសបដិសេធមិនទទួលយកការដាក់ឯកសារនេះដោយយឺតយ៉ាវ និងបានស្នើសុំសហមេធាវី នាំមុខចុះហត្ថលេខា លើបណ្តឹងឧទ្ធរណ៍នេះ ។

១៣. ករណីនេះ សហមេធាវីនាំមុខ បានបដិសេធមិនចុះហត្ថលេខា លើបណ្តឹងឧទ្ធរណ៍នេះទេ ព្រោះនេះ មិនមែនជាតួនាទី សហមេធាវីនាំមុខទេ ។ បន្ទាប់មក លោកស្រី STUDZINSKY បានស្នើសុំឱ្យសហមេធាវី នាំមុខដាក់ឯកសារទាំងពីរនេះ ដោយចុះហត្ថលេខាសហមេធាវីនាំមុខ ទៅអង្គជំនុំជម្រះសាលាដំបូង ហើយ សហមេធាវីនាំមុខ បានយល់ព្រម ។ នេះគឺជាហេតុផលនៃការយឺយ៉ាវពេលវាលាដាក់ឯកសារទាំងនេះ ។

១៤. ជាសរុបមក សហមេធាវីនាំមុខយល់ឃើញថា ឯកសារទាំងនេះ ជាដំបូងបានផ្ញើរជូន សហមេធាវីនាំមុខ ហើយខណៈពេលដែល សហមេធាវីនាំមុខកំពង់តែ ពិនិត្យឯកសារទាំងនោះ លោកស្រី STUDZINSKY

បានបដិសេធពីតួនាទីរបស់សហមេធាវីនាំមុខលើកិច្ចការនេះ ដោយគាត់បានដាក់ឯកសារទាំងនេះ ដោយខ្លួនឯងផ្ទាល់ទៅអង្គជំនុំជម្រះសាលាដំបូងតែម្តង ។ លើសពីនេះ ពេលកាលកំណត់ដាក់ឯកសារហួស គាត់បាន ត្រឡប់មករកសហមេធាវីនាំមុខ ហើយនៅតែ ទទូចថា ការងារនេះមិនស្ថិតក្នុង តួនាទីរបស់ សហមេធាវីនាំមុខទេ ថ្វីបើមានការពន្យល់ក៏ដោយ ។

ចំនុចនេះ វាជាបញ្ហាលើកទីមួយក្នុងការដាក់ឯកសារដោយសហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែ ពួកគាត់នៅតែជឿជាក់ថា ពួកគាត់ទទួលបានលិខិតផ្ទេរសិទ្ធិពីកូនក្តី ដែលអនុញ្ញាតឲ្យពួកគាត់ ដាក់នូវរាល់ញត្តិផ្សេងៗ ជាលក្ខណៈឯកឯង ។ គួរកត់សម្គាល់ថា សម្រាប់កូនក្តីខ្លះ ដើមបណ្តឹងរដ្ឋប្បវេណី មានផលប្រយោជន៍ធំធេងណាស់ដែលឯកសារទាំងពីរនេះគួរត្រូវបានដាក់ និងទទួលយកដោយ អង្គជំនុំជម្រះសាលាដំបូង ។

ហេតុដូច្នេះ សូម្បីតែមានកំហុសនេះក៏ដោយ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បណី សូមស្នើសុំដោយក្តីគោរព ដល់អង្គជំនុំជម្រះ សាលាដំបូងមេត្តា៖

១. ទទួលយកឯកសារទាំងពីរដែលបានភ្ជាប់មកជាមួយនេះ ដោយឯកសារមួយ គឺ ឧបសម្ព័ន្ធ ៥ ដែលត្រូវបានប្រកាសថា ដាក់យឺយ៉ាវ និង ឯកសារ ឧបសម្ព័ន្ធ ៦ ។

២. ទទួលយកការដាក់ឯកសារដែលយឺតយ៉ាវនេះ និង

៣. ដាក់ឯកសារទាំងពីរនេះ ដែលជាសេចក្តីសង្ខេបភ្ជាប់ឧបសម្ព័ន្ធ ៥ និង ៦ ទៅក្នុងសំណុំរឿង ។

សូមអង្គជំនុំជម្រះ សាលាដំបូងមេត្តាទទួលនូវក្តីគោរពដ៏ពីយើងខ្ញុំ ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ២១មីនា២០១១ | ពេជ អង្គ<br>សហមេធាវីជាតិនាំមុខ | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>សហមេធាវីអន្តរជាតិនាំមុខ | ភ្នំពេញ | |